កិច្ចការខ្មែរបំរើព្រះគ្រីស្ទ អន្តរជាតិ
Cambodian Ministries *for* Christ International
Address: # 13C, St.331, Beong kok II, Toul Kork, Phnom Penh, Cambodia.
Tel: 012 856 100. E-mail: t_bunsoeum@cmcnews.org . Website: www.cmcnews.org

# របាយការណ៍ស្តីអំពីសកម្មភាពផ្សេងៗ
# ចាប់ពីខែតុលា ដល់ ខែធ្នូ ឆ្នាំ២០០៩

## I-ផ្នែកសាងសង់:

*អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ បានសាងសង់ អាគារព្រះវិហារចំនួនមួយខ្នង នៅភូមិ សំរោងជ័យ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។ ចំណាយទឹកប្រាក់អស់ចំនួន $១៥៥០០ ក្នុងនោះអង្គការចំណាយទឹកប្រាក់ចំនួន$១១០០០ ហើយពួកជំនុំនៅក្នុងតំបន់ត្រូវជួយថវិកាជាបដិភាគចំនួន$៤៥០០ ។*









## II-ផ្នែកអភិវឌ្ឍន៍សហគមន៍:

*អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ បានប្រវាស់មេគោចំនួន៨ក្បាល អោយទៅប្រជាជនក្រីក្រចំនួន៨គ្រួសារ ។ ឥឡូវនេះ បានប្រវាស់កូនគោនោះជាបន្តទៀតបានចំនួន១១ គ្រួសារហើយ ដែលពួកគាត់កំពុងរស់នៅខេត្តពោធិ៍សាត់ ដូចដែលបានរៀបរាប់ខាងក្រោមនេះ ៖*



១-លោក មឿង សាម៉េត រស់នៅភូមិ ផ្តល់ចែក ឃុំ រលាប ស្រុក សំពៅមាស ខេត្តពោធិ៍សាត់។ បានប្រវាស់មេគោ១ក្បាលពីអង្គការCMC ។
មេគោនេះបង្កើត បានកូនចំនួន១ក្បាលហើយ :

- ១ក្បាលជាចំណែកអង្គការបានប្រវាស់បន្តឲ្យទៅអ្នកស្រី ប៉ែន សុជាតិ ។

ហើយមេនេះមានផ្ទៃពោះទៀតហើយ



២-ឈ្មោះ ប៉ែន សុជាតិ រស់នៅភូមិ លាក់ ឃុំព្រៃត្រឡាច ស្រុកមោងឫស្សី ខេត្តបាត់ដំបង បានប្រវាស់កូនគោមេ១ក្បាលពីអង្គការ ។ ដែលកូនគោនេះជាកូនដែលកើតពីមេគោដែលប្រវាស់លោកមឿង សាម៉េត ។ កូនគោនេះមិនទាន់រកឈ្មោលនៅឡើយទេ ។



៣-លោក ប៉ាង សេរីភាព រស់ភូមិ ទួលគ្រោះ ឃុំ ចំរើនផល ស្រុក សំពៅមាស ខេត្ត ពោធិ៍សាត់។ បានប្រវាស់មេគោ១ក្បាលពីអង្គការCMC ។ មេគោនេះ បង្កើតបានកូនចំនួន២ក្បាលហើយមកដល់ពេលនេះ:

- ១ក្បាលជាចំណែកអង្គការបានប្រវាស់បន្តឲ្យទៅលោក មាស នីម ។
- ១ក្បាលទៀតជាចំណែកអ្នកប្រវាស់ ។

មេវាមិនទាន់រកឈ្មោលទៀតទេ



៤-លោក មាស នីម រស់នៅភូមិ ព្រៃខ្លុង ឃុំរកាត ស្រុកក្រវាញ ខេត្តពោធិ៍សាត់។ បានប្រវាស់កូនគោមេពីអង្គការជាភាគី(ក) ដែលកូនគោនេះមកពីមេគោនៅលោក ប៉ាង សេរីភាព វារកឈ្មោលហើយប៉ុន្តែមិនដឹងថាវាមានផ្ទៃពោះឬអត់



៥-លោក ពូ ព្រៀម រស់នៅភូមិ ក្រហស្តក្បាល ឃុំ
រកាស្រុក ក្រវាញ ខេត្តពោធិ៍សាត់ ។
បានប្រវាស់មេគោ១ក្បាល ពីអង្គការCMC ។
ឥឡូវមេគោនេះ បង្កើតបានកូនចំនួន២ក្បាលហើយ :

- ១ក្បាលជាចំណែករបស់អង្គការហើយបានប្រវាស់ទៅឲ្យ ឈ្មោះឯក វ៉ាន់ថា ។
- ១ក្បាលទៀតជារបស់អ្នកប្រវាស់ ។

ហើយឥឡូវនេះវាមិនទាន់រកឈ្មោលនៅឡើយទេ



៦-ឈ្មោះ ឯក វ៉ាន់ថា រស់នៅភូមិ ក្រហស្តក្បាល ឃុំ
រកាស្រុក ក្រវាញ ខេត្តពោធិ៍សាត់ ។
បានប្រវាស់កូនគោឈ្មោលពីអង្គការ ។
ឥឡូវនេះអាយុរបស់វាជាងមួយខួបហើយ



៧- ឈ្មោះ ស្រី សឿន វិញ រស់នៅភូមិ ក្រហស្តក្បាល
ឃុំ រកាស្រុក ក្រវាញ ខេត្តពោធិ៍សាត់ ។
មេគោនេះមានកូនមេ អាយុចំនួន៩ ខែហើយ។



៨-ឈ្មោះ ទៀង ហៀង រស់នៅភូមិ ព្រៃស្នាច់ ឃុំរកាត
ស្រុក ក្រវាញ ខេត្តពោធិ៍សាត់ ។បានប្រវាស់មេគោ១ ក្បាល
ពីអង្គការCMC ឥឡូវមេគោនេះបង្កើតបានកូន គោឈ្មោល
១ក្បាលគឺជាកូនទី១ដែលជាចំណែករបស់អង្គការCMC។
កូនគោនេះត្រូវបានប្រវាស់ទៅអោយ ឈ្មោះ ភឹម ឡាយ
(ប៉ុន្តែបានងាប់ដោយជម្ងឺហើយកាលពីខែមុន)
ហើយឥឡូវនេះមេគោនេះវាដោយឈ្មោលទៀតហើយ។



៩-លោក សេង ថាណា រស់នៅភូមិប្រឡាយធំ ឃុំ វាល
ស្រុកកណ្ដៀងខេត្ត ពោធិ៍សាត់ ។ បានប្រវាស់ មេគោ១
ក្បាល ពីអង្គការCMC មេគោនេះមិនដែលមានកូនម្ដងណា
ទេ ។ ហើយលោកសេង ថាណាបានយកទៅផ្ញើជាមួយ
បងប្អូននៅឯខេត្តបាត់ដំបង ។ មេនេះមិនដែលមានកូនម្ដង
ណាឡើយ ។



១០-ឈ្មោះ សន ម៉ៅ រស់នៅភូមិថ្លល់ចែក ឃុំរលាប
ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។
បានប្រវាស់មេគោ១ក្បា ពីអង្គការCMC ។
មេគោនេះបង្កើតបានកូនគោមេ១ក្បាលជាកូនទី១
ដែលជាចំណែករបស់អង្គការCMC កូនគោនេះ
បានប្រវាស់ឲ្យឈ្មោះ សន ឡុង។



១១-ឈ្មោះ សន ឡុង រស់នៅភូមិ ថ្លល់ចែក ឃុំ
រលាប ស្រុក សំពៅមាស ខេត្តពោធិ៍សាត់។
បានប្រវាស់មេគោ ១ក្បាល ពីអង្គការ CMC ។

# III-ផ្នែកសង្គមកិច្ចនិងមនុស្សធម៌:

*អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ នៅតែបន្តជួយដល់គ្រូគង្វាលក្រីក្រ ចំនួន៣នាក់ ដែលរស់នៅតាមបណ្តាខេត្តផ្សេងៗ ។ ១-លោកគ្រូ សាំ សាម៉ុន ទទួលបានថវិកាចំនួន$៧០ក្នុង ១ខែ ។ ២-លោកគ្រូ ធី សុង ទទួលបានថវិកាចំនួន$៧០ក្នុង១ខែ ប៉ុន្តែត្រូវបញ្ចប់នៃការឧបត្ថម្ភ នៅក្នុងខែធ្នូ ឆ្នាំ២០០៩នេះ ។ ៣-លោកគ្រូ ជា សុផាត ទទួលបានថវិកាចំនួន$១០០ ក្នុង១ខែ ត្រូវបញ្ចប់នៃការឧបត្ថម្ភនៅខែវិច្ឆិកា ឆ្នាំ២០០៩ នេះដែរ ។*



១-លោកគ្រូ សាំ សាម៉ុន នៅភូមិ
ថ្លល់ជប៉ុន ឃុំរលាប ស្រុកសំពៅ មាស
ខេត្តពោធិ៍សាត់ ។



២-លោកគ្រូ សុង ធី រស់នៅភូមិ កូបតូច
ឃុំគុត្តសត ស្រុកអូរជ្រៅ
ខេត្តបន្ទាយមានជ័យ ។



៣-លោកគ្រូ ជា សុផាត ជាគ្រូ ជំនួយ
នៅពួកជំនុំគ្រាប់ពូជនៃក្តី សង្ឃឹម ភូមិ
ចំបក់ ឃុំ ប្រាសាទ ស្រុកកំពង់ត្របែក
ខេត្តព្រៃវែង ។

*អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិបានបន្តជួយដល់សិស្សក្រីក្រ នៅទីក្រុងភ្នំពេញ មានចំនួន៤នាក់ ៖*



១-ឈ្មោះ សឿម សាមី ភេទ ប្រុស អាយុ១៦ឆ្នាំ

- រៀនថ្នាក់ទី ១១ (រៀននៅសាលាឥន្ទ្រទេវី)
- ឧបត្ថម្ភ ១ខែ$១៥



២-ឈ្មោះ ប៊ូរុណា អ័ប្រាហាំ ភេទ ប្រុស អាយុ១២ឆ្នាំ

- រៀនថ្នាក់ទី៦(រៀននៅសាលា អំបិល និងពន្លឺ អន្តរជាតិ)
- ឧបត្ថម្ភ ១ខែ$១០



៣-ឈ្មោះ សឿម ម៉ារីយ៉ា ភេទ ស្រី អាយុ១៨ឆ្នាំ

- រៀនថ្នាក់ទី៧(រៀននៅសាលា អំបិល និងពន្លឺ អន្តរជាតិ
- ឧបត្ថម្ភ ១ខែ$១៥



៤-ឈ្មោះ សឿម អាម៉ីនិកា ភេទ ស្រី អាយុ១២ឆ្នាំ

- រៀនថ្នាក់ទី៦ (រៀននៅសាលា អំបិល និងពន្លឺ អន្តរជាតិ)
- ឧបត្ថម្ភ ១ខែ$២០

*អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ បានបន្តជួយដល់និស្សិតក្រីក្រ មានចំនួន២នាក់ នៅទីក្រុងភ្នំពេញ ដែលម្នាក់ៗត្រូវបង់ថ្លៃសាលាចំនួន$៣៣០ ក្នុង១ឆ្នាំៗ៖*



ឈ្មោះ ម៉ានិកាម រ៉ាដា ភេទប្រុស អាយុ២៥ឆ្នាំ
រៀននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ
ជានិស្សិតឆ្នាំទី៤ ផ្នែក IT



ឈ្មោះ ម៉ានិកាម សុវណ្ណារី ភេទស្រី អាយុ២៦ឆ្នាំ
រៀននៅសកលវិទ្យាល័យបៀលប្រាយ
ជានិស្សិតឆ្នាំទី៤ ផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ

អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ បានចុះទៅចែកអង្ករ ដល់ប្រជាជនក្រីក្រចំនួន ២៥គ្រួសារ ដែលមានមនុស្សចំនួន ៧៨ នាក់ នៅភូមិកូបតូច ឃុំគុត្តសត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ អង្ករដែលអង្គការបានចែកជូនមានចំនួន ១៩៥០ គីឡូក្រាម ចំណាយទឹកប្រាក់អស់ចំនួន $៩៥០ (ប្រាំបួនពាន់ហាសិបដុល្លារ) ។ ហើយក្នុងនោះ ប្រជាជនម្នាក់ៗទទួលបានអង្ករចំនួន ២៥គីឡូក្រាម ។ ក្នុងពិធីចែកអង្ករនេះមាន លោកមេឃុំ និង មេភូមិអញ្ជើញចូលរួមផងដែរ ។









អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិប្រចាំនៅប្រទេសកម្ពុជា សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះសប្បុរសជនទាំងអស់ ដែលបានជួយឧបត្ថម្ភអាគារព្រះវិហារ ជាថវិកាដល់គ្រូគង្វាល និងជាអង្ករដល់ប្រជាជនក្រីក្រផងដែរ ។ ហើយក៏អរគុណចំពោះ អង្គការកិច្ចការខ្មែរបំរើព្រះគ្រីស្ទអន្តរជាតិ ប្រចាំនៅសហរដ្ឋអាមេរិក ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការទំនាក់ទំនងរកដៃគូជួយមកប្រទេសកម្ពុជា ។

សូមព្រះជាម្ចាស់ប្រទានព្រះពរ ដល់អស់លោកអ្នកបងប្អូនទាំងអស់ អោយបានប្រកបតែសេចក្តីសុខសាន្តនៅក្នុងព្រះគុណព្រះជាអម្ចាស់យេស៊ូវគ្រីស្ទ ។

ភ្នំពេញ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩

ហត្ថលេខា

នាយកប្រចាំប្រទេស



ទូច ប៊ុនសឿម